# ទំនាក់ទំនងរវាងយុវជន និងមនុស្ស ជំនាន់មុននៅកម្ពុជា

## សេចក្តីផ្តើម

កម្ពុជា ស្ថិតក្នុងចំណោមប្រទេសមានប្រជាជនវ័យក្មេងជាងគេនៅអាស៊ីអគ្នេយ៍ ព្រោះប្រមាណ ៦៣% នៃប្រជាជនសរុបមានអាយុក្រោម ៣០ឆ្នាំ។ ដោយឡែក អ្នកមានអាយុពី ១៥ ដល់ ៣០ឆ្នាំ ដែលតាមនិយមន័យក្នុងអត្ថបទនេះ ជាក្រុមយុវជន គឺមានដល់ប្រមាណ ៣៣%។ នៅកម្ពុជា ក្រុមយុវជននេះមានចំនួនភាគរយច្រើនគួរឲ្យកត់សំគាល់ក្នុងចំណោម ប្រជាជនដែលមានសកម្មភាព និងការចូលរួមផ្នែកនយោបាយ។ អ្នកសង្កេតការណ៍ជាច្រើនបានផ្តល់គំនិតថា ការផ្លាស់ប្តូរផ្នែកនយោបាយនាពេលថ្មីៗក្នុងការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន កើតមានជាសំខាន់ដោយសារកំណើនឥទ្ធិពលនៃអ្នកបោះឆ្នោតវ័យក្មេង និងសន្ទុះកម្លាំងនៃមនុស្សជំនាន់ថ្មីនេះ (Eng and Hughes 2017; Mccargo 2014; Un 2015) ។

លក្ខណៈសេដ្ឋកិច្ចសង្គមកិច្ចនៃមនុស្សជំនាន់ថ្មី (យុវជន) ខុសប្លែកគ្នាពីជំនាន់ឪពុកម្តាយរបស់ពួកគេ។ មនុស្សជំនាន់ថ្មីសំដៅដល់អ្នកមានកំណើតនៅចុងទសវត្សរ៍១៩៩០ និងដើមទសវត្សរ៍២០០០ និងបានចម្រើនវ័យក្នុងសម័យមួយមានសន្តិភាព និងស្ថិរភាព មានការបោះឆ្នោតជាទៀងទាត់ មានកំណើនសេដ្ឋកិច្ចខ្លាំងក្លាជាច្រើនទសវត្សរ៍មកហើយ និងមានការផ្លាស់ប្តូររចនាសម្ព័ន្ធយ៉ាងលឿន។ ខុសប្លែកពីយុវជនក្នុងមនុស្សជំនាន់មុន យុវជនជំនាន់ថ្មីមានការអប់រំល្អជាង មានភាពចល័តជាង តែងរកការងារធ្វើនៅតំបន់ទីក្រុង និងមានការតភ្ជាប់នឹងសហគមន៍សកលក្នុងអ៊ិនធើណិត តាមរយៈបណ្តាញសង្គម។ គេអាចវែកញែកថាលក្ខណៈខុសគ្នាខ្លាំងបែបនេះ អាចនាំឲ្យមានទំនាស់រវាងមនុស្សជំនាន់ទាំងពីរ។ ប៉ុន្តែអង្កេតលើប្រជាពលរដ្ឋកម្ពុជាមួយធ្វើឡើងដោយ CDRI នៅឆ្នាំ២០១៧ (ជិតចេញផ្សាយ) បានបង្ហាញផ្ទុយពីនេះ។ ទោះបីមានកង្វះខាតច្រើនក្នុងបទពិសោធន៍នៃជីវិត និងក្នុងស្ថានភាពផ្នែកសេដ្ឋកិច្ចសង្គមកិច្ចក្តី យុវជន និងមនុស្សជំនាន់មុន មានឥរិយាបទស្រដៀងគ្នាចំពោះ គ្រួសារ ទំនាក់ទំនងផ្នែកយេនឌ័រ អាទិភាពក្នុងជីវិត និងតម្លៃផ្នែកវប្បធម៌។ យុវជនផ្តល់អាទិភាពខ្ពស់ដល់កាតព្វកិច្ចក្នុងគ្រួសារ ហើយមនុស្សជំនាន់មុនផ្តល់ការគោរពនិងជួយគាំទ្រដល់យុវជន។

អត្ថបទនេះ បង្ហាញលទ្ធផលសំខាន់ៗនៃការសិក្សាមួយធ្វើឡើងដោយ CDRI ក្នុងឆ្នាំ២០១៧ ដើម្បីពិនិត្យពីកំណើនយុវជននៅកម្ពុជា គំនិតនិងឥរិយាបទរបស់គាត់ និងផលពាក់ព័ន្ធសម្រាប់ការអភិវឌ្ឍសង្គម និងនយោបាយទៅអនាគត។ បន្ទាប់មកមានការពិនិត្យពី ឥរិយាបទ និងការយល់ឃើញរបស់យុវជន និងមនុស្សជំនាន់មុន ចំពោះ យេនឌ័រ ក្រុមគ្រួសារ សង្គម វប្បធម៌ នយោបាយ និងគោលដៅចាំបាច់ក្នុងជីវិត។ ក្នុងសេចក្តីសន្និដ្ឋានមានការបូកសរុបពីលទ្ធផលរកឃើញសំខាន់ៗ បន្ទាប់មកមានការពិភាក្សាពី ហេតុអ្វីបានជាមនុស្សពេញវ័យនៅក្មេង និងមនុស្សជំនាន់មុន មានឥរិយាបទស្រដៀងគ្នា និងក្នុងកាលៈទេសៈបែបណា និងការផ្តល់មតិថា ទាំងអស់នេះជាសញ្ញាល្អសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជាទៅអនាគត។

## យុវជនកម្ពុជាក្នុងពេលមានការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គមកិច្ចយ៉ាងលឿន

ក្របខ័ណ្ឌពេលវេលា និងផលប៉ះពាល់នៃស្ថានភាពប្រជាសាស្ត្ររបស់យុវជន មិនផ្តោតសំខាន់ទៅលើការឈានចូលភាពពេញវ័យរបស់យុវជនឡើយ ប៉ុន្តែផ្តោតសំខាន់លើ បទពិសោធន៍តួនាទីផ្នែកសេដ្ឋកិច្ចសង្គមកិច្ច តម្លៃសីលធម៌ និងរបៀបរស់នៅរបស់យុវជន ដែលខុសប្លែកពីមនុស្សជំនាន់មុន ក្នុងពេលមានការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គមកិច្ចយ៉ាងលឿន និងខ្លាំងក្លា។ យុវជនពុំមានការចងចាំផ្ទាល់ខ្លួន ឬបទពិសោធន៍ផ្ទាល់អំពីការប្រល័យពូជសាសន៍ និងអំពើហិង្សាដែលឪពុកម្តាយ និងយាយតារបស់ខ្លួន បានរងគ្រោះនោះទេ។ ក្នុងអំឡុងពេលដែលពួកគេចម្រើនវ័យ នៅកម្ពុជាមានកំណើនរឹងមាំនិងយូរឆ្នាំ មានកំណែទម្រង់ផ្នែកស្ថាប័ននិងគោលនយោបាយជាច្រើន និងមានការផុសឡើងនូវបច្ចេកវិទ្យាឌីជីថល និងបណ្តាញសង្គម។

កម្ពុជារក្សាបាននូវអត្រាកំណើនប្រចាំឆ្នាំជាមធ្យម ៧,៧% ពីឆ្នាំ១៩៩៥ ដល់ ២០១៧ (World Bank 2017) និងមានការផ្លាស់ប្តូរជាបណ្តើរៗពី ប្រទេសមានប្រភពកំណើនសេដ្ឋកិច្ចចម្បងបានពីវិស័យកសិកម្ម ទៅបានពី ឧស្សាហកម្ម និងសេវាកម្មវិញ។ ការផ្លាស់ប្តូរនេះមានផលពាក់ព័ន្ធច្រើនសម្រាប់យុវជន/ប្រជាជនទសវត្សថ្មី (millennials) ដែលមាន ឱកាសបញ្ហាប្រឈម និងក្តីរំពឹងខុសប្លែកពីឪពុកម្តាយខ្លួន ពាក់ព័ន្ធនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធ ការកាត់បន្ថយភាពក្រីក្រ ព្រមទាំងការរីកលូតលាស់របស់មនុស្ស តាមរយៈកំណើនកម្រិតជីវភាព ការថែទាំសុខភាពនិងការអប់រំកាន់តែប្រសើរ ជាពិសេសក្នុងចំណោមយុវជន។

នៅកម្ពុជា អត្រាភាពក្រីក្របានធ្លាក់ចុះយ៉ាងលឿន ដល់ ១៣,៥% នៅឆ្នាំ២០១៤ ហើយអាចដល់ ក្រោម ១០% នាពេលថ្មីៗនេះទៀត។ ប៉ុន្តែនៅពេលរាប់បញ្ចូលនូវកង្វះខាតក្នុងការ

---

អត្ថបទនេះ រៀបរៀងដោយ ឆុំ ធាវី ជាអ្នកស្រាវជ្រាវ នៅផ្នែកអភិបាលកិច្ចនៃវិទ្យាស្ថាន CDRI។ សូមយោងអត្ថបទនេះថា៖ Chhom Theavy. 2019. “Youth and Older Generation Relations in Cambodia.” *Cambodia Development Review* 22 (2): 7-14.

អប់រំនិងសេវាថែទាំសុខភាពផង អត្រាភាពក្រីក្រអាចឡើងដល់ជិត ៣៥% ក្នុងនេះមាន ៤៥% អាយុក្រោម ១៩ឆ្នាំ (UNDP 2018)។

ការរីកចម្រើន និងលទ្ធផលសេដ្ឋកិច្ចនៅកម្ពុជា នាំឲ្យមានការប្រសើរឡើងគួរឲ្យកត់សំគាល់ក្នុង សូចនាករសំខាន់ៗនៃការអភិវឌ្ឍមនុស្ស ជាពិសេស ការអប់រំ ការថែទាំសុខភាព និងហេដ្ឋារចនាសម្ព័ន្ធ។ ដោយឡែក កម្ពុជាបានកែលំអលទ្ធភាពទទួលបានប្រកបដោយសមធម៌នូវ ការអប់រំកម្រិតបឋមសិក្សាសម្រាប់ក្មេងស្រីក្មេងប្រុសក្រីក្រ និងធូរធារ នៅតំបន់ជនបទ និងទីក្រុង (Lun and Roth 20140)។ ក្នុងឆ្នាំសិក្សា២០១៦ អត្រាចុះឈ្មោះចូលរៀនសុទ្ធនៅបឋមសិក្សា មានដល់ ៩៨% ហើយអត្រារៀនចប់ មានដល់ ៨០% រីឯអត្រារៀនចប់អនុវិទ្យាល័យមានដល់ ៤៣% (MOEYS 2017) ។

វត្តមាន និងលទ្ធភាពបានទទួលការអប់រំកម្រិតបឋមសិក្សាបង្ហាញថា យុវជនសព្វថ្ងៃមានកម្រិតអប់រំខ្ពស់ជាងឪពុកម្តាយខ្លួន។ អង្កេតលើអន្តរកាលពីសាលារៀនទៅដល់ការងារ (SWTSs) ដែលបានធ្វើឡើងឃ្លាតគ្នា ២ឆ្នាំ បានរកឃើញថា មានយុវជន ៥៤% បានរៀនចប់ថ្នាក់ខ្ពស់ជាងឪពុកខ្លួន ហើយ ៦២,៨% បានរៀនចប់ថ្នាក់ខ្ពស់ជាងម្តាយខ្លួន នៅឆ្នាំ២០១៤ (NIS and ILO 2015, 15) ធៀបនឹង អត្រា ៤៨,៦% និង ៦២,៨% រៀងគ្នានៅឆ្នាំ២០១២ (Heang, Khieu and Elder 2013, 2)។

ថ្វីបើការសម្រេចបានកម្រិតអប់រំ នៅមានកម្រិតទាបនៅឡើយ ប៉ុន្តែអត្រាគ្មានការងារធ្វើរបស់យុវជនត្រឹម ២,៤% គឺទាបណាស់ បើធៀបនឹងប្រទេសភាគច្រើន ហើយអត្រាទាបនេះ អាចបណ្តាលមកពីកម្ពុជាមានការងារច្រើន ទាំងសម្រាប់ពលករមិនមានជំនាញ និងមានជំនាញទាប (NIS and ILO 2015, 3)។ ក្នុងចំណោមយុវជនកំពុងបម្រើការងារ មាន ៥១% ជាអ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់បំណាច់ (unpaid family workers) ៣៣% ជាពលករទទួលបៀវត្សរ៍ ១៦% ជាអ្នកប្រើប្រាស់ទុនផ្ទាល់ខ្លួន (own-account workers) និង តិចជាង ១% ជានិយោជក។ គិតតាមវិស័យសេដ្ឋកិច្ចចម្បងៗ យុវជន ៤៧% បម្រើការក្នុងកសិកម្ម ៣១% ក្នុងសេវាកម្ម និង ២២% ក្នុងឧស្សាហកម្ម (NIS and ILO 2015, 29) ។ ទោះបីជាអត្រាមានការងារធ្វើមានកម្រិតខ្ពស់ ក្នុងចំណោមយុវជនក៏ដោយ ការពិតជាក់ស្តែងគឺ ការទទួលបានការងារសមរម្យវានៅមិនទាន់មានច្រើនគ្រប់គ្រាន់នោះទេ។ ជារឿយៗ យុវជនបម្រើការងារមានគុណភាពអន់ ក្នុងរូបភាពជា ប្រាក់ឈ្នួលទាប ការងារមិនទៀងទាត់ឬយូរម៉ោង និងតួនាទីបណ្តោះអាសន្ន។

ការប្រែក្លាយផ្នែករចនាសម្ព័ន្ធ បានជួយបង្កើនភាពចល័ត និងឱកាសការងារសម្រាប់យុវជន ហើយកំណើនយ៉ាងលឿននៃអ៊ិនធើណិត ក៏ដូចជាបច្ចេកវិទ្យាថ្មីៗ (កុំព្យូទ័រយួរដៃ តាប្លែត និងទូរស័ព្ទឆ្លាត) បានពង្រីកដែនឥទ្ធិពលរបស់វា។ មួយភាគបីនៃយុវជនកម្ពុជា មានអ៊ិនធើណិតប្រើប្រាស់ ក្នុងនោះមាន ៤០% តែងប្រើអ៊ិនធើណិតយ៉ាងហោចណាស់ ១ដង/ថ្ងៃ (BBC Media Action 2014)។

សង្គមកម្ពុជា ក៏បានផ្លាស់ប្តូរគួរឲ្យកត់សំគាល់ដែរ។ មានការផ្លាស់ប្តូរយ៉ាងច្បាស់ ឆ្ពោះទៅកាន់ភាពស្មើគ្នាក្នុងរបៀបរបបផ្នែកយេនឌ័រ និងការក្លាយខ្លួនជាជនគំរូ ហើយទាំងអស់នេះប្រហែលអាចជាប់ពាក់ព័ន្ធនឹងការផ្តល់សិទ្ធិអំណាច និងលទ្ធភាពរបស់ស្ត្រី ក្នុងការចោទជាសំណួរទៅលើតួនាទីស្ត្រីតាមប្រពៃណីជាអ្នកក្រោមបង្គាប់ និងតួនាទីយេនឌ័រ។ ទោះបីមានផ្លាស់ប្តូរច្រើនក្តី គ្រួសារនៅតែសំខាន់ខ្លាំងក្នុងផ្នត់គំនិតជាទូទៅ និងជះឥទ្ធិពលទៅលើសឹងតែគ្រប់អន្តរកម្មក្នុងសង្គម (Karbaum 2015; Pen, Hok and Eng 2017)។ ក្នុងអង្កេតលើអន្តរកាលពីសាលារៀនទៅដល់ការងារ (SWTSs) ឆ្នាំ២០១៤ មានយុវជន ៤២% បានជ្រើសយក "ការកសាងជីវិតគ្រួសារល្អ" ជាគោលដៅចម្បងក្នុងជីវិត គឺសំខាន់ជាង ទ្រព្យធន ការងារ ការអប់រំ និងការចូលរួមចំណែកក្នុងសង្គមទៅទៀត (NIS and ILO 2015, 18) ។ ភាពខុសគ្នា រវាងទីក្រុង-ជនបទ និងធនធានសេដ្ឋកិច្ចរបស់គ្រួសារនានា ក៏សំខាន់ដែរ ក្នុងការកំណត់លំនាំថ្មីនៃវិសមភាព។ យុវជនធូរធារនៅទីក្រុង ច្រើនក្លាយជាអ្នករៀនចប់សាកលវិទ្យាល័យ រីឯយុវជនធូរធារនៅជនបទ តែងកែលំអវាសនាខ្លួនដោយធ្វើជាពលករចំណាកស្រុក (Peou 2013)។

ការរីកចម្រើនយ៉ាងលឿននៅកម្ពុជា ត្រូវបានសម្រួល និងពង្រឹងឡើង តាមការភ្ជិតបានជិតដល់ ៦៨% នៃគម្លាតផ្នែកយេនឌ័រសរុប (WEF 2017) ធ្វើឲ្យកម្ពុជាចូលក្នុងចំណោម ១០ប្រទេសនៅអាស៊ី ដែលសម្រេចបានភាពស្មើគ្នាផ្នែកយេនឌ័រល្អជាងគេ (WEF 2018)។ ការសិក្សានេះ គាំទ្របន្ថែមលើលទ្ធផលនៃការសិក្សាពីមុនៗ ជាពិសេស ភាពខុសគ្នាក្នុងតួនាទីផ្នែកយេនឌ័រដែលបានសាបរលាបទៅជាបណ្តើរៗ សម្រាប់ទាំងមនុស្សជំនាន់ថ្មី និងជំនាន់មុន។

## វិធីសាស្ត្រ និងក្របខ័ណ្ឌយកសំណាកក្នុងអង្កេត

អង្កេតនេះបានធ្វើឡើងក្នុង ៥ខេត្ត គឺ បាត់ដំបង កំពតស្ទឹងត្រែង ស្វាយរៀង និង កំពង់ចាម និងនៅក្រុងភ្នំពេញ ពីខែតុលា ២០១៧ ដល់ មករា ២០១៨ ដោយប្រើវិធីសាស្ត្រការជ្រើសរើសសំណាកគំរូតាមដំណាក់កាលដោយចៃដន្យនូវ អ្នកឆ្លើយសម្ភាសន៍ ១.៦០០នាក់ ពីក្នុង ១០១ភូមិ។ ភូមិនានាត្រូវបានជ្រើសរើសតាមដំណាក់កាលផ្អែកលើទីតាំងនៅក្នុងជនបទ និងទីក្រុង ហើយអ្នកឆ្លើយសម្ភាសន៍ត្រូវបានបែងចែកជា យុវជន (អាយុ ១៥-៣០ឆ្នាំ) និង មនុស្សជំនាន់មុន (អាយុច្រើនជាង ៣០ឆ្នាំ) និងបែងចែកតាមភេទ។ គ្រោងសំណាកសម្រាប់អ្នកឆ្លើយសម្ភាសន៍គឺមាន យុវជន ៣៩៨នាក់, មនុស្សជំនាន់មុន ១.២០២នាក់, ហើយ ស្ត្រី៦០%, បុរស៤០%។ កម្រងបញ្ជីសំណួរមានសរុប ១០០សំណួរ ហើយគេប្រើវាតាមរយៈការធ្វើសម្ភាសន៍ទល់មុខនៅតាមផ្ទះអ្នកឆ្លើយសម្ភាសន៍។ វិធីជ្រើសរើសសំណាក ព្រមទាំង

រូបភាព១៖ កម្រិតអប់រំរបស់ យុវជន និង មនុស្សជំនាន់មុន




រូបភាព២៖ ចំនួនភាគរយអ្នកឆ្លើយសម្ភាសន៍ធ្លាប់បានធ្វើចំណាកស្រុក (N=1600)




រូបភាព៣៖ ចំនួនភាគរយអ្នកឆ្លើយសម្ភាសន៍ធ្លាប់បានផ្លាស់ប្ដូរការងារក្នុងមួយឆ្នាំមុន




រូបភាព៤៖ ការប្រើប្រាស់អ៊ីនធើណិត (N=1600)




ការប្រើព័ត៌មានផ្នែកប្រជាសាស្ត្រដែលមានស្រាប់ បានជួយឲ្យក្រុមស្រាវជ្រាវអាចកាត់បន្ថយជាអតិបរមានូវ លំអៀងក្នុងការជ្រើសរើស និងការប្រែប្រួលជាធម្មតាក្នុងការជ្រើសរើសសំណាកដោយសាររបាយនៃប្រជាជន។ ដូច្នេះលទ្ធផលរកឃើញក្នុងអង្កេតនេះ តំណាងឲ្យប្រជាជនកម្ពុជាទាំងមូល។

## ចំណុចសំខាន់ៗបានពីលទ្ធផលរកឃើញក្នុងអង្កេត

### *លក្ខណៈសេដ្ឋកិច្ចសង្គមកិច្ចនៃយុវជន និងមនុស្សជំនាន់មុននៅកម្ពុជា*

លក្ខណៈខុសប្លែកគ្នារវាងយុវជន និងមនុស្សជំនាន់មុន អាចមើលឃើញកាន់តែច្បាស់ ហើយចំណាប់អារម្មណ៍របស់សាធារណជនពីភាពខុសគ្នានេះ ក៏ឃើញច្បាស់ដែរក្នុងអង្កេតនេះ។ យុវជន ៦៦% និង មនុស្សជំនាន់មុន ៨១% បានយល់ស្របថា មានភាព "ខុសគ្នាខ្លាំង" រវាងពីរជំនាន់ពួកគាត់នេះ។

*កម្រិតអប់រំសម្រេចបាន៖* យុវជនកម្ពុជាមានលទ្ធភាពទទួលបានការអប់រំ និងសម្រេចបានកម្រិតអប់រំ ខ្ពស់ជាងឪពុកម្ដាយខ្លួន។ ដូចមានចុះក្នុង រូបភាព១ មានមនុស្សជំនាន់មុន ក្នុងចំនួនច្រើនជាងយុវជន ដែលបានរៀនចប់បឋមសិក្សា និងអនុវិទ្យាល័យ ប៉ុន្តែមានយុវជនច្រើនជាង ដែលមានការអប់រំកម្រិតវិទ្យាល័យ និងសាកលវិទ្យាល័យ។

*ប្រភេទមុខរបរ៖* ភាពខុសគ្នារវាងជនបទ-ទីក្រុង នៅតែកំណត់និន្នាការក្នុងការបម្រើការងារ (តារាង១)។ ប៉ុន្តែយុវជនកម្ពុជា

តារាង១៖ មុខរបរចម្បង (%) (N=1587)

| | សរុប | ក្រុមអាយុ | | ភេទ | | ទីតាំង | |
|---|---|---|---|---|---|---|---|
| | | យុវជន | មនុស្សជំនាន់មុន | ប្រុស | ស្ត្រី | ជនបទ | ទីប្រជុំជន |
| កសិករ | 36 | 25 | 40 | 40 | 34 | 46 | 8 |
| បុគ្គលិករដ្ឋ | 6 | 2 | 7 | 10 | 3 | 3 | 12 |
| បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល | 0 | 0 | 0 | 0 | 0 | 0 | 1 |
| នយោជិតមានបៀវត្សរ៍ | 13 | **24** | **9** | 17 | 10 | 12 | 14 |
| អ្នកប្រើប្រាស់ទុនផ្ទាល់ខ្លួន | 24 | 15 | 28 | 22 | **26** | 19 | 40 |
| អ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់បំណាច់ | 14 | 18 | 13 | 3 | **22** | 13 | 18 |
| និស្សិត | 4 | 14 | 0 | 4 | 3 | 4 | 3 |
| គ្មានការងារធ្វើ | 3 | 2 | 3 | 4 | 2 | 3 | 4 |

រូបភាព៥៖ តើអ្នកយល់ស្របដែរថា ឲ្យក្មេងប្រុសទៅរៀនសាកលវិទ្យាល័យ វាប្រសើរជាងឲ្យក្មេងស្រីទៅរៀនសាកលវិទ្យាល័យ? (N=1600)




រូបភាព៦៖ តើអ្នកយល់ស្របដែរថា យេនឌ័រជាឧបសគ្គរារាំងជោគជ័យ (N=1,600)




រូបភាព៧៖ តើអ្នកយល់ស្របដែរថា បុរសធ្វើជាអ្នកដឹកនាំនយោបាយប្រសើរជាងស្ត្រី? (N=1600)




រូបភាព៨៖ តើអ្នកយល់ស្របដែរថា ជាការអាចទទួលយកបាន បើសិនយុវជនជំទាស់នឹងគំនិតរបស់ឪពុកម្តាយខ្លួន? (N=1600)




នៅជនបទ ទោះបីចូលចិត្តការងារកសិកម្មក្តី តែងតែព្យាយាមចាកចេញពីតំបន់ជនបទ ដើម្បីរកការងារល្អនៅតាមទីក្រុង។ មានយុវជនជានិយោជិតទទួលបៀវត្សរ៍ ច្រើននាក់ជាងមនុស្សជំនាន់មុន។ បុរសមានច្រើនជាងគេនៅក្នុងការងារមានប្រាក់បៀវត្សរ៍ ហើយស្ត្រីច្រើនតែបម្រើការឲ្យខ្លួនឯង (អ្នកប្រើប្រាស់ទុនផ្ទាល់ខ្លួន និងអ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់បំណាច់) ដែលគេតែងចាត់ទុកជាការងារងាយរងគ្រោះ។

*ភាពចល័ត/ចំណាកស្រុក៖* ដូចមានចុះក្នុង រូបភាព២ មានយុវជន (៣២%) ច្រើននាក់ជាង មនុស្សជំនាន់មុន (២៥%) ដែលធ្វើចំណាកស្រុកដើម្បីរកការងារធ្វើ ហើយចំណុចនេះវាពិតសម្រាប់ យុវជននៅជនបទ (៣៧%) និងមនុស្សជំនាន់មុននៅជនបទ (២៨%)។ យុវជន (១៤%) ច្រើនតែផ្លាស់ប្តូរការងារជារឿយៗជាង មនុស្សជំនាន់មុន (៩%) (រូបភាព៣)។

*លទ្ធភាពប្រើប្រាស់អ៊ិនធើណិត៖* យុវជនមានការតភ្ជាប់នឹងអ៊ិនធើណិត ច្រើនជាងមនុស្សជំនាន់មុន ពោលគឺ ៦១% នៃយុវជនកំពុងប្រើប្រាស់អ៊ិនធើណិត ធៀបនឹង ២៦% នៃមនុស្សជំនាន់មុន (រូបភាព៤)។ ក្នុងចំណោម ៣៥% នៃអ្នកឆ្លើយសម្ភាសន៍ដែលគេរកឃើញថាជាអ្នកប្រើអ៊ិនធើណិត គឺមានអ្នកប្រើអ៊ិនធើណិត

រូបភាព៩៖ ការដាក់ពិន្ទុតាមលំដាប់សារៈសំខាន់នៃកត្តាផ្នែកសង្គមនានា (N=1600)



តារាង២៖ អ្នកណាជះឥទ្ធិពលខ្លាំងជាងគេទៅលើការយល់ឃើញផ្នែកនយោបាយរបស់អ្នក (N=1433)

| | 1st | | 2nd | | 3rd | | 4th | | 5th | | 6th | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន | យុវជន | មនុស្សជំនាន់មុន |
| គ្រួសារ | **32** | 28 | 18 | 19 | 17 | 19 | 19 | 20 | 15 | 18 | 8 | 12 |
| អាជ្ញាធរផ្នែកនយោបាយ | 31 | 28 | **32** | 31 | 19 | 20 | 12 | 12 | 6 | 11 | 0 | 0 |
| ប្រព័ន្ធផ្សព្វផ្សាយ | 22 | 25 | 18 | 18 | **19** | 14 | 13 | 16 | 16 | 18 | 17 | 15 |
| គ្រូបង្រៀន | 10 | 10 | 17 | 15 | 19 | 17 | 20 | 19 | 20 | 16 | 7 | 9 |
| អាជ្ញាធរផ្នែកសាសនា | 3 | 7 | 9 | 11 | 10 | 15 | 17 | 13 | 17 | 15 | 41 | 28 |
| អ្នករួមការងារ | 3 | 2 | 6 | 6 | 16 | 14 | 20 | 21 | 27 | 21 | 28 | 36 |

តាមរយៈទូរស័ព្ទឆ្លាត (៨៤%) កុំព្យូទ័រផ្ទាល់ខ្លួន (៩%) កុំព្យូទ័រនៅការិយាល័យ (៥%) និង កុំព្យូទ័រសាធារណៈ (២%)។

សរុបមក ទោះបីមានលក្ខណៈផ្នែកសេដ្ឋកិច្ចសង្គមកិច្ចខុសគ្នាក្នុងការសម្រេចបានកម្រិតអប់រំ ភាពមានការងារធ្វើ ភាពចល័ត និង លទ្ធភាពបានប្រើប្រាស់អ៊ិនធើណិតក្តី ក៏យុវជន និងមនុស្សជំនាន់មុន មានឥរិយាបទស្រដៀងគ្នាចំពោះតួនាទីនៃគ្រួសារ និងទំនាក់ទំនងជិតស្និទ្ធក្នុងគ្រួសារ។

## *ឥរិយាបថ និងការប្រមើលឃើញរបស់យុវជន និងមនុស្សជំនាន់មុននៅកម្ពុជា*

ទី១ អត្ថបទនេះបង្ហាញពី ឥរិយាបទ និងការប្រមើលឃើញរបស់យុវជនចំពោះ សមភាពផ្នែកយេនឌ័រក្នុងការអប់រំ របាំងរារាំងជោគជ័យ តួនាទីជាអ្នកដឹកនាំ តម្លៃសីលធម៌ផ្នែកសង្គមនិងនយោបាយនៅក្នុងគ្រួសារខ្លួន ជីវិតផ្ទាល់ខ្លួន និងសិទ្ធិអំណាចធ្វើការសម្រេចចិត្ត។ បន្ទាប់មកមានការពិនិត្យពីចំណូលចិត្ត និងអាទិភាពក្នុងជីវិតរបស់យុវជន។ ជាទូទៅ គ្រួសារនៅតែជះឥទ្ធិពលខ្លាំងជាងគេទៅលើ ឥរិយាបទ និងការប្រមើលឃើញផ្នែកសង្គមនិងនយោបាយ របស់យុវជន។

ការវិភាគស្ថិតិអង្កេតបានរកឃើញថា យុវជន និងមនុស្សជំនាន់មុន មានឥរិយាបថ និងចំណាប់អារម្មណ៍ស្រដៀងគ្នាចំពោះទិដ្ឋភាពនីមួយៗដែលបានសិក្សា ឬនិយាយម្យ៉ាងទៀតថា គ្មានការខុសប្លែកគ្នាគួរឲ្យកត់សំគាល់ទេរវាងយុវជន នឹងមនុស្សជំនាន់មុន។

ជាទូទៅ មានការទទួលស្គាល់កម្រិតខ្ពស់ពីសមភាពផ្នែកយេនឌ័រក្នុងការអប់រំ ការងារ អាជីព និង ភាពជាអ្នកដឹកនាំផ្នែកនយោបាយ (រូបភាព ៥, ៦, ៧) ឬនិយាយដោយសាមញ្ញថា មានភាពលំអៀងផ្នែកយេនឌ័រតិចតួចណាស់ ក្នុងទិដ្ឋភាពទាំង ៣ នេះ។ ចំណុចនេះអាចឆ្លុះបញ្ចាំងពី កំណើនចំណាប់អារម្មណ៍ផ្ទាល់ខ្លួនពី ផ្នត់គំនិត និងបែបបទជាប្រពៃណីនានា។ ជាឧទាហរណ៍ យុវជន (៨២%) និងមនុស្សជំនាន់មុន (៧៣%) ភាគច្រើនយល់ស្របថា ក្មេងប្រុស និងក្មេងស្រី គួរមានឱកាសដូចៗគ្នា។ ម្យ៉ាងទៀត មានយុវជនត្រឹម ២៣% និងមនុស្សជំនាន់មុនត្រឹម ៣១% ប៉ុណ្ណោះ ដែលគិតថា យេនឌ័រជាឧបសគ្គរារាំងជោគជ័យ ហើយផ្តល់មតិថា បែបបទផ្នែកយេនឌ័របានថយចុះឥទ្ធិពលជាបណ្តើរៗ ក្នុងលក្ខណៈជាកត្តាកំណត់ជោគជ័យ។ ទោះយ៉ាងនេះក្តី សម្រាប់ភាពជាអ្នកដឹកនាំផ្នែកនយោបាយវិញ មានការយល់ស្របគ្នាច្រើនណាស់ក្នុងចំណោម យុវជន (៤៣%) និងមនុស្សជំនាន់មុន (៤២%) លើគំនិតថា បុរសធ្វើជាអ្នកដឹកនាំផ្នែកនយោបាយបានល្អជាងស្ត្រី។

ឪពុកម្តាយនៅតែរក្សាតួនាទីស្នូល មិនត្រឹមតែក្នុងការទទួលបានការគោរព និងការមានសិទ្ធិអំណាចជាឪពុកម្តាយនោះទេ ប៉ុន្តែ ពួកគាត់មានឥទ្ធិពលដល់ ការជ្រើសរើសអាទិភាពជីវិតសំខាន់ៗរបស់យុវជន ហើយទាំងអស់នេះជះឥទ្ធិពលទៅលើការសម្រេចចិត្ត និងការប្រមើលឃើញផ្នែកនយោបាយរបស់យុវជន។ ៤៥% នៃយុវជន និង ៤០% នៃមនុស្សជំនាន់មុន នៅបន្តប្រតិបត្តិតាមតម្លៃសីលធម៌ជាប្រពៃណីនៃការអត់ឱន ការគោរព និងប្រតិបត្តិតាមឪពុកម្តាយ (រូបភាព៨)។ គ្រួសារទទួលបានចំណាត់ថ្នាក់ជា ទិដ្ឋភាពសង្គមសំខាន់បំផុតពីសំណាក់ ៧៨% នៃយុវជន និង ៦៥% នៃមនុស្សជំនាន់មុន ហើយចំណាត់ថ្នាក់សំខាន់ទី២ គឺ ការអប់រំនិងការងារសម្រាប់យុវជន (៤៥%) និងសាសនាសម្រាប់មនុស្សជំនាន់មុន (៣១%) (រូបភាព៩)។ ស្រដៀងគ្នាដែរ សម្រាប់សំណួរថា តើនរណាដែលជះឥទ្ធិពលលើទស្សនៈនយោបាយរបស់អ្នក គឺ គ្រួសារទទួលបានចំណាត់ថ្នាក់ថាមានឥទ្ធិពលសំខាន់បំផុត ពីសំណាក់ យុវជន ៣២% បន្ទាប់មកគឺ អាជ្ញាធរផ្នែកនយោបាយ និងបន្ទាប់មកទៀត ប្រព័ន្ធផ្សព្វផ្សាយ (តារាង២)។ សម្រាប់ការទទួលបានព័ត៌មានផ្នែកនយោបាយ គ្រួសារជាប្រភពទី២ គឺនៅក្រោម ទូរទស្សន៍ (រូបភាព១០)។ យុវជន (៦១%) និងមនុស្សជំនាន់មុន (៥៨%) តែងចែករំលែកគំនិតនិងក្តីបារម្ភ និងចំណាយពេលនៅជាមួយក្រុមគ្រួសារខ្លួន។

ដូចមានចុះក្នុង រូបភាព១១ ការធ្វើសេចក្តីសម្រេចចិត្តភាគច្រើនគឺជារបស់យុវជនផ្ទាល់ ប៉ុន្តែឪពុកម្តាយដើរតួនាទីសំខាន់ក្នុងការសម្រេចចិត្តធំៗក្នុងជីវិត ដូចជា ការរៀបការ និងការអប់រំ

រូបភាព១១៖ តើអ្នកណាធ្វើសេចក្តីសម្រេចចុងក្រោយសម្រាប់យុវជនលើបញ្ហាទាំងនេះ? (N=1,592-1,596)




រូបភាព១០៖ តើអ្នកទទួលបានព័ត៌មានផ្នែកនយោបាយមកពីប្រភពណា? (N=1600)



រូបភាព១២៖ ការដាក់ពិន្ទុរបស់អ្នកឆ្លើយសម្ភាសន៍តាមលំដាប់សារៈសំខាន់នៃ អាទិភាពសំខាន់ៗទាំង ៥ ក្នុងជីវិត (N=1,587-1,589)




ដែលតែងតែជាសេចក្ដីសម្រេចរួមគ្នា។ ចំណុចនេះអាចមកពីការអប់រំ និងការរៀបការ វាជះឥទ្ធិពលយូរអង្វែងដល់ជោគជ័យរបស់បុគ្គលក្នុងមួយជីវិត។

### *ការប្រមើលឃើញរបស់យុវជនពីអនាគតកាល*

អ្នកឆ្លើយសម្ភាសន៍ត្រូវបានស្នើឲ្យដាក់ពិន្ទុ ពី ១ (មិនសំខាន់) ដល់ ៥ (សំខាន់ក្រៃលែង) លើអាទិភាពសំខាន់ៗ ៥ ក្នុងជីវិត។ លទ្ធផលចុះក្នុង រូបភាព១២ មិនមានបង្ហាញពីភាពខុសគ្នាគួរឲ្យកត់សំគាល់នោះទេ លើការជ្រើសរើសអាទិភាពនានាក្នុងជីវិតរបស់យុវជន និងមនុស្សជំនាន់មុន។

"ធ្វើឲ្យឪពុកម្ដាយមានមោទនភាព" គឺសំខាន់ក្រៃលែងសម្រាប់យុវជន ៨០% ដែលអាចដោយសារយុវជនមានអារម្មណ៍ត្រូវដឹងគុណឪពុកម្ដាយ ហើយ "ការក្លាយជាជនគំរូ" វាសំខាន់ក្រៃលែងដែរសម្រាប់ យុវជន ៦៦%។ លទ្ធផលទាំងនេះបង្ហាញថា យុវជនភាគច្រើន មានគំនិតវិជ្ជមានចំពោះជីវិតនៅពេលប្រឹងប្រែងសម្រេចជោគជ័យ។ ចំណុចមិនបានរំពឹងទុក គឺ "ការរៀនចប់ឧត្តមសិក្សា" ជាកត្តាសំខាន់ក្រៃលែងសម្រាប់យុវជន ៤៣%។ លទ្ធផលនេះអាចឆ្លុះបញ្ចាំងខ្លាំងជាងនូវ កំហិតរ៉ាំរ៉ៃនៅក្នុងប្រព័ន្ធអប់រំ ជាជាង មហិច្ឆតា និងសមត្ថភាពរបស់យុវជន។ សរុបមក យុវជននៅតែផ្ដល់តម្លៃដល់គ្រួសារ ជាជាង ទ្រព្យធន និង ការអប់រំ។

## សេចក្ដីសន្និដ្ឋាន

ទោះបីមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច និងនិន្នាការផ្នែកប្រជាសាស្ត្រដូច្នេះក្ដី ក៏មិនឃើញមានភស្តុតាងអ្វីបង្ហាញពីទំនាស់រវាងជំនាន់មនុស្សខុសៗគ្នាលើការយល់ឃើញពី ទិដ្ឋភាពផ្សេងៗនៃជីវិតក្នុងផ្នែកសង្គម នយោបាយ និងវប្បធម៌នោះទេ។ ទាំងយុវជន និងមនុស្សជំនាន់មុន ផ្ដល់តម្លៃខ្ពស់ស្រដៀងគ្នាដល់គ្រួសារ ទំនាក់ទំនងផ្នែកយេនឌ័រ និងអាទិភាពផ្សេងៗក្នុងជីវិត។ គ្រួសារតែងរក្សាបាននូវ តួនាទីជាប្រពៃណីរបស់ខ្លួនជាទិដ្ឋភាពដ៏សំខាន់បំផុតមួយនៃជីវិត ហើយតែងជះឥទ្ធិពលក្នុងកម្រិតណាមួយទៅលើការប្រមើលឃើញពីសង្គមនិងនយោបាយ និងការធ្វើសេចក្ដីសម្រេចចិត្ត។ យុវជនសព្វថ្ងៃ មានលក្ខណៈឯករាជ្យជាងយុវជនជំនាន់មុន ហើយតែងធ្វើការសម្រេចចិត្ត និងការជ្រើសរើសផ្សេងៗក្នុងជីវិតរបស់ខ្លួន។ មនុស្សជំនាន់មុនតែងគោរព និងជួយគាំទ្រយុវជន ដោយផ្ដល់សិទ្ធិអំណាចឲ្យយុវជនកាន់តែច្រើនក្នុងការសម្រេចចិត្ត។ ការបែងចែកតួនាទីផ្នែកយេនឌ័រកំពុងតែសាបរលាបទៅហើយក្នុងក្រុមអាយុទាំងពីរនេះ។

ការសិក្សាជាច្រើនបានគូសរំលេចពី សារៈសំខាន់នៃ តួនាទីគ្រួសារនៅក្នុងសង្គមប្រកបដោយឋានានុក្រមនៅកម្ពុជា និងពីបែបបទជាប្រពៃណី ដែលទំនាក់ទំនងក្នុងសង្គមតែងវិលវល់នៅក្នុងគ្រួសារ ហើយទំនុកចិត្តក៏តែងឃើញមានតែក្នុងគ្រួសារដែរ (Inada 2013; Eng et al. 2019)។ ចំណុចនេះនៅតែពិត

សម្រាប់យុវជន ពីព្រោះពួកគេឲ្យតម្លៃដល់ការរៀបការ សាសនា និងគ្រួសារ ខ្ពស់ជាង ការលំហែកំសាន្ត និងសកម្មភាពក្នុងសហគមន៍។ ឪពុកម្ដាយតែងមើលឃើញជាសំខាន់ថា ការចូលរួមរបស់គាត់គឺ ដើម្បីឲ្យយុវជនបានជ្រោតជ្រាបពីកាតព្វកិច្ចត្រូវគោរព និងប្រតិបត្តិតាមឱវាទឪពុកម្ដាយ។ ឪពុកម្ដាយមានឥទ្ធិពលស្នូលក្នុងជីវិត និងសេចក្ដីសម្រេចរបស់យុវជន ជាប្រភពព័ត៌មានដ៏សំខាន់ផ្នែកនយោបាយ និងមានឥទ្ធិពលខ្លាំងបំផុតលើទស្សនៈនយោបាយរបស់យុវជន។

យុវជនមិនមែនសុទ្ធតែផ្សារភ្ជាប់ទាំងស្រុងទៅនឹង របៀបរបបជាប្រពៃណីនៃគ្រួសារនោះទេ។ អង្កេតស្រាវជ្រាវនេះ បានផ្ដល់ភស្តុតាងថា ភាពខុសគ្នាផ្នែកយេនឌ័រកំពុងថយចុះក្នុងចំណោមយុវជន និងមនុស្សជំនាន់មុន។ លទ្ធផលស្រាវជ្រាវបង្ហាញពីការយល់ស្របកម្រិតខ្ពស់ ឲ្យមានសមភាពក្នុងឧត្តមសិក្សា ការយល់ស្របកម្រិតខ្ពស់ថា យេនឌ័រមិនមែនជាឧបសគ្គរារាំងជោគជ័យនោះទេ និង ការរើសអើងខ្លះៗប្រឆាំងនឹងអ្នកដឹកនាំនយោបាយជាស្ត្រី។ ប៉ុន្តែក្នុងចំណុចទាំងអស់នេះ នៅតែមានគម្លាតផ្នែកយេនឌ័រនៅឡើយ។ លទ្ធផលនេះអាចឆ្លុះបញ្ចាំងពីការពិតជាក់ស្ដែងដែល តាមរយៈ អ៊ិនធើណិត បណ្ដាញសង្គម ឱកាសបានទទួលការសិក្សាអប់រំ លទ្ធភាពចល័តខ្លួនចុះឡើង ក្រុមយុវជនតែងដឹងព័ត៌មានច្រើនជាងមនុស្សជំនាន់មុន។

អង្កេតស្រាវជ្រាវនេះ បានទាក់ទាញការយកចិត្តទុកដាក់ច្រើនណាស់ទៅលើ តួនាទីដ៏សំខាន់នៃតម្លៃសីលធម៌របស់គ្រួសារក្នុងអាទិភាពជីវិត ការសម្រេចចិត្ត និង ឥទ្ធិពលលើផ្នែកនយោបាយរបស់យុវជន។ ការប្រល័យពូជន៍សាសន៍ និងសង្គ្រាម ក្នុងប្រវត្តិសាស្ត្រកម្ពុជា និងការរីកវរក្នុងសង្គម និងសេដ្ឋកិច្ចនៅក្រោមរបបផ្ដាច់ការជាបន្តបន្ទាប់ បានបន្សល់ទុកនូវស្លាកស្នាមយ៉ាងជ្រៅក្នុងសង្គមកម្ពុជា។ ជាលទ្ធផលរចនាសម្ព័ន្ធនិងវប្បធម៌របស់គ្រួសារ ហើយនិងទំនាក់ទំនងក្នុងសង្គមរបស់គ្រួសារ នៅតែជាកត្តាកំណត់នៃដំណើរជីវិតផ្នែកសេដ្ឋកិច្ច និងនយោបាយ។ យុវជនមានការតាំងចិត្តកាន់តែខ្ពស់ក្នុងការបំពេញតាមក្ដីរំពឹង និងកាតព្វកិច្ចក្នុងគ្រួសារ ជាជាងការស្វែងរកសម្រាប់ខ្លួនឯងនូវ សុខមាលភាព ប្រាក់ចំណូល ទ្រព្យធន និងការអប់រំ។ ដោយសារគ្រួសារមានឥទ្ធិពលខ្លាំងជាងគេទៅលើដំណើរជីវិតរបស់យុវជន ដូច្នេះការសិក្សាដើម្បីបង្កើនការយល់ដឹងពីទិដ្ឋភាពផ្នែកសេដ្ឋកិច្ច នយោបាយ សង្គម និងកាតព្វកិច្ចជាពលរដ្ឋ ដែលកំណត់បំណងប្រាថ្នារបស់យុវជនគួរចាប់ផ្ដើមពីការវិភាគនៅកម្រិតគ្រួសារ។

កត្តាផ្សេងៗ ពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច (ការផ្លាស់ប្ដូរតួនាទីផ្នែកយេនឌ័រ ការសម្រេចបានការសិក្សាថ្នាក់ឧត្ដមសិក្សា លទ្ធភាពមានការងារនិងអាជីពកាន់តែប្រសើរ ការប្រើប្រាស់អ៊ិនធើណិតកាន់តែច្រើន) សុទ្ធតែដើរតួនាទីសំខាន់ក្នុងការស្វែងយល់ពីឥរិយាបថផ្នែកនយោបាយនិងសង្គម និងទំនាក់ទំនងរវាងមនុស្សជំនាន់ខុសគ្នា រីឯការបែងចែករវាងជនបទ-ទីក្រុងអាចសំខាន់ខ្លះដែរ ប៉ុន្តែប្រហែលមិនប៉ះពាល់ដល់អន្តរកម្មផ្សេងទៀតទេ។ ដូច្នេះ គោលនយោបាយរបស់រដ្ឋាភិបាលគួរពង្រីក និងពង្រឹងចំណុចផ្ដោតណាដែលស្របតាមលទ្ធភាព ការយកចិត្តទុកដាក់ និងបំណងប្រាថ្នារបស់យុវជន។ ការប្រឹងប្រែង និងពេលវេលា គួរផ្ដោតលើ ទាំងការព្យាយាមកែលំអការអប់រំនិងការងាររបស់យុវជនយុវនារី និងការព្យាយាមទាញយកអត្ថប្រយោជន៍ឲ្យបានច្រើនថែមទៀត ពីការចូលរួមរបស់យុវជននៅក្នុងនយោបាយ និងការអភិវឌ្ឍ។

## ឯកសារយោង


BBC Media Action. 2014. "Youth in Cambodia: Media Habits and Information Sources." Phnom Penh: BBC Media Action Research and Learning.

Eng Netra and Caroline Hughes. 2017. "Coming of Age in Peace, Prosperity, and Connectivity: Cambodia's Young Electorate and Its Impact on the Ruling Party's Political Strategies." *Critical Asian Studies* 49 (3): 396–410.

Eng Netra, Ang Len, So Hengvotey, Hav Gechhong and Chhom Theavy. Forthcoming. *Cambodia's Young and Older Generation: Views on Generational Relations, and Key Social and Political Issues*. Working Paper. Phnom Penh: CDRI.

Heang Kanol, Khieu Khemarin and Sara Elder. 2013. *Labour Market Transitions of Young Women and Men in Cambodia*. Work4Youth Publication Series No. 2 Geneva: ILO.

Inada, Juichi. 2013. "Analysis of the Survey on Social Capital in Cambodia." *Senshu Social Capital Review* 4: 161–89.

Karbaum, Markus. 2015. "The Dynamics of Social Change in Cambodia. Moving Away from Traditionalism?" *Internationales Asienforum* 46 (3–4): 229–259.

Lun Pide and Roth Vathana. 2014. "How Unequal Is Access to Opportunities in Cambodia." *Cambodia Development Review* 18 (2): 6–11.

Mccargo, Duncan. 2014. "Cambodia in 2013: (No) Country for Old Men?" *Asian Survey* 54 (1): 71–77.

MOEYS (Ministry of Education, Youth and Sport). 2017. "The Education, Youth and Sport Performance in the Academic Year 2015-2016 and Goals for the Academic Year 2016-2017." www.moeys.gov.kh/en/education-congress-2017/reports.html#.XIB1-igzbIU.

NIS and ILO (National Institute of Statistics and *International Labour Organization)*. 2015. "Labour Market Transitions of Young Women and Men in Cambodia 2014." Phnom Penh: Ministry of Planning.

Pen Rany, Hok Kimhean and Eng Netra. 2017. *Cambodia's Young Generation: A State of Art Review*. Working Paper Series No. 113. Phnom Penh: CDRI.

Peou, Chivoin. 2013. "Growing up in Cambodian Society: Stratification of Passages into Migrant Labor Workers and Urban Graduates." In *Proceedings of the Australian Sociological Association Conference*, Melbourne, 25–28 Nov 2013.

UNDP (United Nations Development Programme). 2018. "Clarification: Multidimensional Poverty is decreasing in Cambodia." www.kh.undp.org/content/cambodia/en/home /presscenter/pressreleases/2018/clarification--multidimensional-poverty-is-decreasing-in-cambodi.html.

Un Kheang. 2015. "The Cambodian People Have Spoken: Has the Cambodian People's Party Heard?" *Southeast Asian Affairs* 2015 (1): 102–116.

WEF (World Economic Forum). 2017. "The Global Gender Gap Report 2017." Geneva: WEF.

WEF. 2018. www.weforum.org/agenda/2018/09/asia-gender-equal-countries/.

World Bank. 2017. "The World Bank in Cambodia: Overview." www.worldbank.org/en/ country/cambodia/ overview.